# ការរៀនសូត្រ និងអង្គការដែលមានចរិតរៀនសូត្រ

By Leng Chhay

## ការរៀនសូត្រជាអ្វី?

ក្នុងបរិបទប្រទេសកម្ពុជា ការរៀនសូត្រមានន័យថាទៅសាលារៀន ហើយស្តាប់គ្រូបង្រៀន។ ការរៀនសូត្រ បែបទន្ទេញត្រូវបានគេប្រើប្រាស់ជាញឹកញាប់ក្នុងប្រព័ន្ធអប់រំចាស់របស់កម្ពុជា។ សិស្សមានទស្សនៈថា គ្រូត្រូវមានចំនេះដឹងខ្ពស់ជាងខ្លួនជានិច្ច ដូច្នេះហើយបានជាមានការរំពឹងទុកនូវ ចំលើយ "ខុស" ឬ "ត្រូវ" ពីគ្រូ ចំពោះសំនួរដែលសិក្ខាកាមសួរ។ ក្នុងវប្បធម៌ខ្មែរ ជាទូទៅគ្រូទទួលបាន ការគោរពយ៉ាងច្រើនពីសិស្ស។

ក្នុងបរិបទអភិវឌ្ឍន៍ការរៀនសូត្រមានការផ្សារភ្ជាប់នឹងការផ្លាស់ប្តូរ។ រាល់ការផ្លាស់ប្តូរអាកប្បកិរិយា មានន័យថាការរៀនសូត្រកំពុងឬបានកើតឡើងហើយ។ ជារឿយៗមនុស្សរៀនសូត្រពីបទពិសោធន៍ និងពីកំហុសរបស់គេ។ ការរៀនសូត្រមិនមែនគ្រាន់តែស្តាប់គ្រូ ឬអ្នកសំរបសំរួលប៉ុណ្ណោះទេ ប៉ុន្តែ វាជាដំណើរការមួយនៃការរុករក គិត វិភាគ ស្វែងរក និងអនុវត្ត។ ការរៀនសូត្របែបបចូលរួម ឬការរៀនសូត្រដែលផ្តោតលើអ្នករៀនមានលក្ខណៈសមស្របចំពោះបរិបទអភិវឌ្ឍន៍ ពីព្រោះវាជួយ អភិវឌ្ឍសមត្ថភាពអ្នករៀនក្នុងការគិត វិភាគ និងទាញចេញនូវមេរៀនឬដំណោះស្រាយដោយ ខ្លួនគេ។

## អង្គការដែលមានចរិតរៀនសូត្រជាអ្វី?

រហូតមកដល់ពេលនេះ ទស្សនៈអង្គការមានចិតរៀនសូត្រហាក់ដូចជានៅថ្មី និងមិនទាន់មានការ យល់ដឹងទូលំទូលាយចំពោះ អង្គការជាច្រើននៅឡើយ នៅប្រទេសកម្ពុជា។ Peddler និងអ្នកនិពន្ធរួមជាមួយគាត់ បានអោយ និយមន័យអង្គការមានចរិតរៀនសូត្រថា ជាអង្គការមួយដែលសំរបសំរួលការរៀនសូត្រដល់ បុគ្គលិកទាំងអស់របស់គេ ហើយធ្វើការផ្លាស់ប្តូរខ្លួនឯងជាបន្តបន្ទាប់។ គោលបំណងនៃអង្គការមានចរិត រៀនសូត្រ គឺដើម្បីធ្វើអោយអង្គការមានការលូតលាស់ និងរស់រានមានជីវិត។

ក្នុងអត្ថបទ "អង្គការមិនមែនរដ្ឋាភិបាលជាអង្គការមានចរិតរៀនសូត្រ" លោក James Taylor បានសរសេរលក្ខណៈវិនិច្ឆ័យ៤ សំរាប់ចាត់ទុកថាអង្គការមួយ ជាអង្គការដែលមានចរិតរៀនសូត្រ៖

1. វាមិនមែនជាអង្គការដែលគ្រាន់តែរៀនប៉ុណ្ណោះទេ ប៉ុន្តែជាអង្គការដែលរៀនដោយស្មារតីភ្ញាក់រលឹក។
2. អង្គការនោះបានសំរេចការប្រតិបត្តិដែលមានលក្ខណៈប្រសើរឡើង។ អង្គការអាចអនុវត្តសកម្មភាពនានាដែលចាំបាច់សំរាប់ដោះស្រាយបញ្ហា និងឧបសគ្គ ហើយលើកកំពស់ការអនុវត្ត។
3. អង្គការនោះរៀនសូត្រជាបន្តបន្ទាប់ដើម្បីសំរេចបានតុល្យភាពសមស្រប រវាងការឆ្លុះបញ្ចាំង ការរៀនសូត្រ និងការធ្វើសកម្មភាព។
4. អង្គការនោះអភិវឌ្ឍមធ្យោបាយនិងសមត្ថភាពនានាដើម្បីទាញយកផលប្រយោជន៍អោយបានពេញលេញពីបទសកម្មភាពនិងបទពិសោធន៍របស់ខ្លួនដែលជាប្រភពមូលដ្ឋានសំរាប់ការរៀនសូត្រ។

ចុះអង្គការអ្នកវិញ?

The article is shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.